00349458

D138/1/8

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

*តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី*
*ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម*
*ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ១៨)

**ចំពោះមុខ:** ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**ក្រឡាបញ្ជី:** សរ ចន្ទរ៉ាត
Entela JOSIFI

**កាលបរិច្ឆេទ:** ១៣ ខែកក្កដា ឆ្នាំ២០០៩

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 13 / JUL / 2009
ម៉ោង (Time/Heure): 14 : 45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

**សាធារណៈ:**

## សាលដីកាលើភាពអាចទទួលយកបាននៃ "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អំពីការរំលោភបំពានការសម្ងាត់នៃកិច្ចស៊ើបសួរ"

---

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 13 / JUL / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**សហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**ជនត្រូវចោទ**
អៀង សារី

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE
Pierre Olivier SUR
Elizabeth RABESANDRATANA
Olivier BAHOUGNE
David BLACKMAN
Annie DELAHAIE

**សហមេធាវីការពារក្តី**
អាង ឧត្តម
Michael G. KARNAVAS

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អ.វ.ត.ក" បានទទួល "បណ្តឹងឧទ្ធរណ៍ [របស់សហមេធាវីការពារក្តីលោក អៀង សារី ] ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីការរំលោភបំពានការសម្ងាត់នៃកិច្ចស៊ើបសួរ" ("បណ្តឹងឧទ្ធរណ៍") ដែលបានដាក់នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២00៩។

## សេចក្តីផ្តើម

១. នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២00៩ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចអំពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ "ដីកាសម្រេចអំពីភាពសម្ងាត់" ដែលសម្រេចណែនាំដល់សហមេធាវីការពារក្តី អៀង សារី គឺលោកមេធាវី Michael G. KARNAVAS និងលោកមេធាវី អាង ឧត្តម។

២. នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២00៩ សហមេធាវីការពារក្តីលោក អៀង សារី បានដាក់បណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះប្រឆាំងនឹងដីកាសម្រេចអំពីភាពសម្ងាត់ និងបានស្នើសុំកាលបរិច្ឆេទនៃការដាក់ឯកសារឲ្យបានឆាប់រហ័ស និងបើកសវនាការដេញដោលផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍ជាសាធារណៈ។

៣. នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២00៩ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ "សារណា" ទៅអង្គបុរេជំនុំជម្រះទាក់ទងនឹងបណ្តឹងឧទ្ធរណ៍។

៤. នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២00៩ សហព្រះរាជអាជ្ញាបានដាក់ "សេចក្តីអង្កេត"ទៅអង្គបុរេជំនុំជម្រះទាក់ទងនឹងបណ្តឹងឧទ្ធរណ៍។

៥. នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២00៩ ដើមបណ្តឹងរដ្ឋប្បវេណីគ្មានមេធាវីតំណាង សេង ចាន់ធារី បានដាក់សេចក្តីថ្លែងការណ៍ទៅអង្គបុរេជំនុំជម្រះទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ និងបានស្នើសុំ "សិទ្ធិក្នុងការឡើងនិយាយដោយខ្លួនឯងផ្ទាល់ [នៅក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍នេះ]"។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00349460



៦. នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានចេញសេចក្តីបង្គាប់ដល់សហមេធាវីការពារក្តីលោកអៀង សារី ទាក់ទងនឹង "សេចក្តីអង្កេត" របស់សហព្រះរាជអាជ្ញាលើបណ្តឹងឧទ្ធរណ៍។ នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៩ សហមេធាវីការពារក្តីលោក អៀង សារី បានដាក់សេចក្តីឆ្លើយតបរបស់ខ្លួន ទៅនឹងសេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះក្តី។

## បញ្ហានីតិវិធីបឋមទាក់ទងនឹងបណ្តឹងឧទ្ធរណ៍នេះ

៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា បញ្ហានីតិវិធីបឋមចំនួនបួន ដែលបានលើកឡើងក្នុងសារណារបស់សហមេធាវីការពារក្តីលោក អៀង សារី សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងដើមបណ្តឹងរដ្ឋប្បវេណីវេណីគ្មានមេធាវីតំណាង សេង ចាន់ធារី មានដូចខាងក្រោមនេះ៖

១. តើភាគីណាមួយមានសិទ្ធិជាភាគីដាក់បណ្តឹងឧទ្ធរណ៍នេះ[1]។

២. តើសហព្រះរាជអាជ្ញាជាភាគីនៃបណ្តឹងឧទ្ធរណ៍នេះដែរឬទេ[2]។

៣. តើដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២[3] រួមទាំងដើមបណ្តឹងរដ្ឋប្បវេណីគ្មានមេធាវីតំណាង សេង ចាន់ធារី[4] ជាភាគីនៃបណ្តឹងឧទ្ធរណ៍នេះដែរឬទេ។

៤. សំណើសុំបើកសវនាការដេញដោលផ្ទាល់មាត់[5]។

---

[1] សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ដែលជំទាស់ទៅនឹងដីកាសម្រេចអំពីភាពសម្ងាត់របស់សហចៅក្រមស៊ើបអង្កេត" ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩, D138/1/5 ("សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា") កថាខណ្ឌ៣ និងកថាខណ្ឌ៦។

[2] សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៥។

[3] សារណារបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ក.ស.ច.ស អំពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ ("សារណារបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី") ថ្ងៃទី២៦ ខែមីនា ឆ្នាំ ២០០៩, D138/1/3 កថាខណ្ឌ៥។

[4] សេចក្តីថ្លែងការណ៍របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីគ្មានតំណាង [សេង ចាន់ធារី] ស្តីពីបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារីប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីការរំលោភបំពានការសម្ងាត់នៃកិច្ចស៊ើបសួរ" ("សេចក្តីថ្លែងការណ៍របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីគ្មានតំណាង") ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៩, D138/1/4, កថាខណ្ឌ៣។

[5] សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១០-១៤។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

## I. តើភាគីណាមួយមានសិទ្ធិជាភាគីដាក់បណ្តឹងឧទ្ធរណ៍នេះ

៨. នៅក្នុង "សេចក្តីអង្កេត"របស់ខ្លួន សហព្រះរាជអាជ្ញាបានលើកឡើងនូវបញ្ហាដូចខាងក្រោមនេះ៖

> "សហព្រះរាជអាជ្ញាសង្កេតឃើញថា អង្គបុរេជំនុំជម្រះអាចពិចារណាច្រានចោលបណ្តឹងឧទ្ធរណ៍ ដោយខ្វះជំហរគាំទ្រនៃដើមបណ្តឹងឧទ្ធរណ៍ អៀង សារី ។ ដីកាសម្រេចអំពីភាពសម្ងាត់ ត្រូវបានចេញស្របតាមវិធាន៣៥ និងវិធាន៣៨ នៃវិធានផ្ទៃក្នុង ប្រឆាំងទៅលើតែមេធាវីការពារក្តីតែប៉ុណ្ណោះ។ អាស្រ័យហេតុនេះ ដើមបណ្តឹងឧទ្ធរណ៍ អៀង សារី មិនមានជំហរដាក់បណ្តឹងឧទ្ធរណ៍នេះទេ ហើយដីកាសម្រេចលើភាពសម្ងាត់ ក៏មិនបានផ្តល់សំអាងនៃបណ្តឹងដើម្បីដាក់ស្នើទៅអង្គបុរេជំនុំជម្រះដែរ។ ទោះបីដើមបណ្តឹងឧទ្ធរណ៍ មានសិទ្ធិប្តឹង និងសំអាងនៃបណ្តឹងក៏ដោយ បណ្តឹងឧទ្ធរណ៍នេះក៏មិនត្រូវបានអនុញ្ញាតដែរ យោងតាមវិធាន៧៤(៣) ដែលបានរៀបរាប់គ្មានសល់ពីប្រភេទនៃបណ្តឹងឧទ្ធរណ៍ ដែលជនត្រូវចោទអាចនាំមកនៅចំពោះមុខអង្គបុរេជំនុំជម្រះ។
>
> [...]
>
> បណ្តឹងឧទ្ធរណ៍នេះ ដូចបានបង្ហាញ បានដាក់ដោយជនត្រូវចោទ អៀង សារី។ អៀង សារី គ្មានជំហរដាក់បណ្តឹងឧទ្ធរណ៍នេះទេ ហើយដីកាសម្រេចលើភាពសម្ងាត់ ក៏មិនបានផ្តល់ឱ្យគាត់នូវសំអាងបណ្តឹងដើម្បីដាក់បណ្តឹងឧទ្ធរណ៍នេះដែរ។ ដីកាសម្រេចលើភាពសម្ងាត់ មិនបានចេញដោយប្រឆាំងនឹង អៀង សារី ទេ។ បណ្តឹងឧទ្ធរណ៍មិនបានបង្ហាញថា គាត់បានទទួលរងនូវភាពលំអៀង ឬការបដិសេធនូវសិទ្ធិណាមួយ ដែលចាំបាច់ត្រូវមានការដោះស្រាយ ដោយអង្គបុរេជំនុំជម្រះតាមការប្តឹងឧទ្ធរណ៍ឡើយ"[6]។

៩. នៅក្នុង "ចម្លើយតបទៅនឹងសេចក្តីបង្គាប់ ដែលចេញដោយអង្គបុរេជំនុំជម្រះនៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩" សហមេធាវីការពារក្តីបានរៀបរាប់ថា៖

---

[6] សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៣ និង៦។

"នេះគឺជាសហមេធាវីការពារក្តី ជាអ្នកដែលមានសិទ្ធិដើម្បីដាក់ប្តឹងឧទ្ធរណ៍មិនមែនលោក អៀង សារី នោះទេ ថ្វីត្បិតតែលោក អៀង សារី យល់ស្របទាំងស្រុងជាមួយសហមេធាវីការពារក្តីថា ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីការរំលោភបំពានភាពសម្ងាត់នៃកិច្ចស៊ើបសួរ ("ដីកាសម្រេចស្តីពីភាពសម្ងាត់") គំរាមរំលោភបំពានដល់សិទ្ធិទទួលបានដំណើរការនីតិវិធីតុលាការប្រកបដោយតម្លាភាព និងមានយុត្តិធម៌។ ការភ័ន្តច្រឡំណាមួយទាក់ទងនឹងអត្តសញ្ញាណនៃភាគីដាក់បណ្តឹង មិនបណ្តាលឱ្យមានការបដិសេធចោលនូវបណ្តឹងឧទ្ធរណ៍ឡើយ។

[...]

៣. បណ្តឹងឧទ្ធរណ៍នេះមានចំណងជើងថា "បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់[សហចៅក្រមស៊ើបអង្កេត] អំពីការរំលោភបំពានការសម្ងាត់នៃកិច្ចស៊ើបសួរ និងសំណើសុំដាក់កាលបរិច្ឆេទដាក់ឯកសារជាបន្ទាន់ និងសវនាការផ្សព្វផ្សាយផ្ទាល់មាត់ជាសាធារណៈ"។ នេះប្រហែលជាអាចធ្វើឱ្យគេយល់ខុសថា បណ្តឹងឧទ្ធរណ៍នេះត្រូវបានដាក់ជួសមុខឱ្យលោក **អៀង សារី**។ ប៉ុន្តែ ឃ្លាដំបូងរបស់សេចក្តីផ្តើម នៃបណ្តឹងឧទ្ធរណ៍អាចធ្វើឱ្យការយល់ច្រលំនានា នៅក្នុងរឿងនេះច្បាស់លាស់ដោយពន្យល់ថា នេះគឺជា "សហមេធាវីការពារក្តីរបស់លោក អៀង សារី គឺលោក អាង ឧត្តម និងលោក Michael G. Karnavas ("ក្រុមមេធាវីការពារក្តី") ដែលជាអ្នកដាក់ពាក្យបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង "ដីកាសម្រេចស្តីពីការរំលោភបំពានភាពសម្ងាត់នៃកិច្ចស៊ើបសួរ"។ សូមបញ្ជាក់ឱ្យច្បាស់លាស់ថា បណ្តឹងឧទ្ធរណ៍នេះត្រូវបានដាក់ដោយសហមេធាវីការពារក្តីរបស់លោក អៀង សារី នៅក្នុងនាមផ្ទាល់ខ្លួនរបស់គេ ខណៈដែលសហមេធាវីការពារក្តី គឺជាកម្មវត្ថុនៃដីកាសម្រេចរបស់ [ក.ស.ច.ស]"[7]។

១០. ផ្អែកលើសារណានានារបស់សហមេធាវីការពារក្តី អង្គបុរេជំនុំជម្រះយល់ឃើញថា សហមេធាវីការពារក្តីលោក អៀង សារី មានសិទ្ធិជា "ភាគីដាក់បណ្តឹង" ចំពោះបណ្តឹងឧទ្ធរណ៍នេះ។

---

[7] សេចក្តីឆ្លើយតបរបស់សហមេធាវីការពារក្តីរបស់លោក អៀង សារី ទៅនឹងសេចក្តីបង្គាប់ដែលចេញដោយអង្គបុរេជំនុំជម្រះ កាលពីថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ ("សេចក្តីឆ្លើយតបរបស់សហមេធាវីការពារក្តីតបទៅនឹងសេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះ") ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៩, D138/1/7 កថាខណ្ឌ២-ក និងកថាខណ្ឌ៣។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

## II. តើសហព្រះរាជអាជ្ញា ជាភាគីទៅនឹងបណ្តឹងឧទ្ធរណ៍នេះដែរឬទេ។

១១. នៅក្នុង "សេចក្តីអង្កេតរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចអំពីភាពសម្ងាត់របស់សហចៅក្រមស៊ើបអង្កេត" ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានលើកឡើងនូវបញ្ហាដូចខាងក្រោមនេះ៖

> "បញ្ហានៃការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលយុត្តិធម៌ ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងការប្រមាថ មាននៅក្នុងយុត្តាធិការជាតិ និងអន្តរជាតិមួយចំនួន គឺជាបញ្ហាច្រើនដែលមានរវាងតុលាការ និងជនល្មើសដែលបានចោទប្រកាន់។ ហេតុដូចនេះ សហព្រះរាជអាជ្ញាមិនបានចាត់ទុកខ្លួនឯងថា ជាគូភាគីពេញលេញចំពោះដំណើរការនីតិវិធីទាំងនេះទេ ប៉ុន្តែគ្រាន់តែជា "ភាគីដែលចាប់អារម្មណ៍" ជាមន្ត្រីនៃតុលាការនេះតែប៉ុណ្ណោះ។ តាមតួនាទីមានកម្រិតក្នុងបណ្តឹងឧទ្ធរណ៍នេះ និងវិសាលភាពចំពោះផលវិបាកដ៏តូចចង្អៀតនៃសេចក្តីសង្កេតនេះ សហព្រះរាជអាជ្ញាមិនបានប្រកាន់យកគោលជំហរណាមួយអំពីអង្គហេតុទាំងអស់ក្នុងសារណា ដែលបានធ្វើឡើងដោយដើមបណ្តឹងឧទ្ធរណ៍នេះទេ លើកលែងតែអ្វីដែលសហព្រះរាជអាជ្ញាលើកឡើងផ្ទាល់ក្នុងសេចក្តីសង្កេតនេះ"[8]។

១២. នៅក្នុង "ចម្លើយតបរបស់ខ្លួនទៅនឹងសេចក្តីបង្គាប់ ចេញដោយអង្គបុរេជំនុំជម្រះនៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៨" សហមេធាវីការពារក្តីបានលើកឡើងថា៖

> "ចំពោះបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ននេះ វាមិនមានការពាក់ព័ន្ធដល់មេធាវីការពារក្តីថា តើសហព្រះរាជអាជ្ញា ("ក.ស.ព") ត្រូវបានគេពិចារណាថា ជាភាគីពេញលក្ខណៈ ឬ គ្រាន់តែជាភាគីដែលមានផលប្រយោជន៍នៃបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ននេះ
> [...]"[9]។

---

[8] សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៥។

[9] សេចក្តីឆ្លើយតបរបស់សហមេធាវីការពារក្តីតបទៅនឹងសេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ២-គ។

១៣. អង្គបុរេជំនុំជម្រះសង្កេតឃើញថា បណ្ដឹងឧទ្ធរណ៍នេះទាក់ទងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលរកឃើញថា សហមេធាវីការពារក្ដីទទួលខុសត្រូវចំពោះទង្វើក្នុងការរំលោភបំពានគោលការណ៍នៃភាពសម្ងាត់ក្នុងការស៊ើបអង្កេត ដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថា ទង្វើនេះអាចត្រូវផ្ដន្ទាទោសតាមវិធាន៣៥ និងវិធាន៣៨ នៃវិធានផ្ទៃក្នុង។ វិធាន៣៥ និងវិធាន៣៨ បានចែងអំពីទង្វើនៃ“ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ” និង“កំហុសវិជ្ជាជីវៈរបស់មេធាវី”។ តួនាទីរបស់សហព្រះរាជអាជ្ញា មិនចាំបាច់ពង្រីករហូតដល់ករណីទាក់ទងនឹងទង្វើ ដែលមានចែងនៅក្នុងវិធាន៣៥ និងវិធាន៣៨ នៃវិធានផ្ទៃក្នុងនោះទេ។

១៤. តួនាទីរបស់សហព្រះរាជអាជ្ញាតាមវិធានផ្ទៃក្នុង អ.វ.ត.ក គឺកំណត់ដាច់ខាតត្រឹមរឿងក្ដីដែលកំពុងចាត់ការ និងការស៊ើបអង្កេតបទល្មើសក្រោមយុត្តាធិការរបស់អ.វ.ត.ក[10]។ ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីបទល្មើសនានាដែលបានប្រព្រឹត្តនៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ (“ច្បាប់អ.វ.ត.ក”) ចែងអំពីបញ្ជីឈ្មោះឧក្រិដ្ឋកម្មក្រោមយុត្តាធិការ អ.វ.ត.ក។ ទង្វើក្នុងការចេញដីកាសម្រេចអំពីភាពសម្ងាត់របស់សហចៅក្រមស៊ើបអង្កេត មិនមានចែងនៅក្នុងបញ្ជីឈ្មោះឧក្រិដ្ឋកម្មនោះទេ។ អង្គបុរេជំនុំជម្រះយល់ឃើញថា តួនាទីរបស់សហព្រះរាជអាជ្ញាមិនត្រូវពង្រីកជាស្វ័យប្រវត្តិ រហូតដល់នីតិវិធីទាក់នឹងការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ និង/ឬកំហុសវិជ្ជាជីវៈរបស់មេធាវីនោះទេ។

១៥. ក្នុងការគាំទ្រទឡ្ហីករណ៍របស់ខ្លួន ដែលចាត់ទុកខ្លួនឯងគ្រាន់តែជា “ភាគីដែលចាប់អារម្មណ៍” ជា “មន្ត្រីនៃតុលាការនេះ” សហព្រះរាជអាជ្ញាបានលើកឡើងនូវឧទាហរណ៍ចំនួនពីរចេញពីការអនុវត្តន៍របស់អង្គជំនុំជម្រះតុលាការICTY[11] ដែលលើកឡើងថា តុលាការអាចស្នើសុំឱ្យរដ្ឋអាជ្ញាចូលរួម ឬជួយនៅក្នុងដំណាក់កាលដំបូង និង/ឬនៅក្នុងដំណើរការនីតិវិធីបណ្ដឹងឧទ្ធរណ៍ ក្នុងករណីទាក់ទងនឹងបទចោទប្រកាន់អំពីការប្រមាថតុលាការ។

---

[10] វិធានផ្ទៃក្នុងរបស់អ.វ.ត.ក, វិធាន៤៩, ៥០ និង៥៣។

[11] សេចក្ដីសង្កេតរបស់សហព្រះរាជអាជ្ញា, ជើងទំព័រលេខ៥ និង៦។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

១៦. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មិនមានចែងអំពីនីតិវិធីទាក់ទងនឹងទង្វើដែលជា "ការប្រមាថតុលាការ"នោះទេ។ វិធានផ្ទៃក្នុងមិនបានចែងជាក់លាក់អំពីភាគីណាខ្លះ ត្រូវបានចាត់ទុកថាជាភាគីក្នុងរឿងក្ដី ពីបទការប្រមាថតុលាការ។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះត្រូវការស្វែងរកការណែនាំ ដែលមានចែងនៅក្នុងវិធាននីតិវិធីអន្តរជាតិ[12]។

១៧. វិធាន ៧៧(គ)(i) នៃវិធាននីតិវិធី និងភស្តុតាងនៃតុលាការICTY បានចែងថា៖

> "វិធាន៧៧៖ ការប្រមាថតុលាការ
>
> [...]
>
> (គ) នៅពេលអង្គជំនុំជម្រះមានមូលហេតុ និងជឿជាក់យ៉ាងច្បាស់ថា បុគ្គលម្នាក់រូបអាចប្រមាថតុលាការ អង្គជំនុំជម្រះអាច៖
>
> (i) ណែនាំឱ្យរដ្ឋអាជ្ញាស៊ើបអង្កេតបញ្ហានេះ ក្នុងបំណងដើម្បីចូលរួម និងចេញដីកាចោទប្រកាន់អំពីបទប្រមាថតុលាការ[...]"[13]។

១៨. វិធាន៧៧(គ)(i) នៃវិធាននីតិវិធី និងភស្តុតាងរបស់តុលាការICTR បានចែងបទប្បញ្ញត្តិដូចគ្នានៅក្នុងករណីនេះ។

១៩. វិធាន១៧១ នៃវិធាននីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ចែងអំពីករណីស្រដៀងគ្នាទៅនឹងករណី ដែលកំពុងចាត់ការចំពោះមុខអង្គបុរេជំនុំជម្រះ។ វិធានរបស់តុលាការ ICC ហាក់ដូចជាមិនបានចែង អំពីតួនាទីរបស់រដ្ឋអាជ្ញានៅក្នុងករណីបែបនេះទេ។

---

[12] មាត្រា១២ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

[13] វិធាន៧៧ នៃវិធាននីតិវិធីនិងភស្តុតាងរបស់តុលាការICTY។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

២០. អង្គបុរេជំនុំជម្រះយល់ឃើញថា តួនាទីរបស់អ្នកស៊ើបអង្កេតលើការប្រមាថដំណើការនីតិវិធីរបស់តុលាការ អាចត្រូវផ្តល់តួនាទីនេះដល់រដ្ឋអាជ្ញា នៅក្នុងអំឡុងពេលនៃដំណើរការនីតិវិធីដំបូង។ នីតិវិធីចំពោះមុខអង្គបុរេជំនុំជម្រះនេះ គឺ ជានីតិវិធីឧទ្ធរណ៍។ ទាក់ទងនឹងដំណើរការនីតិវិធីនេះ វិធាននៃនីតិវិធី និងភស្តុតាងរបស់តុលាការអន្តរជាតិនានា បានចែងដូចខាងក្រោមនេះ៖

២១. វិធាន១១៧ នៃវិធាននីតិវិធី និងភស្តុតាងរបស់តុលាការICTR បានចែងថា៖

> "វិធាន១១៧៖ ការពន្លឿននីតិវិធីឧទ្ធរណ៍
>
> (ក) បណ្តឹងឧទ្ធរណ៍ដូចមានចែងក្នុងវិធាន [...]៧៧ ត្រូវបើកសវនាការឲ្យបានឆាប់រហ័ស ដោយផ្អែកលើមូលដ្ឋាននៃកំណត់ហេតុដើមរបស់អង្គជំនុំជម្រះសាលាដំបូង។ [...]
>
> (ខ) វិធាន១០៩ ដល់វិធាន១១៤ មិនត្រូវអនុវត្តចំពោះបណ្តឹងឧទ្ធរណ៍បែបនេះទេ"។

២២. វិធាន១១៦ *ស្ទួន* ក្នុងជំពូកទី៧ នៃវិធាននីតិវិធី និងភស្តុតាងរបស់តុលាការICTY ចែងទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ដូចមានចែងនៅក្នុងវិធាន៧៧ (ការប្រមាថ) ដូចខាងក្រោមនេះ៖

> "(ក) ត្រូវបើកសវនាការឲ្យឆាប់រហ័ស ដោយផ្អែកលើមូលដ្ឋាននៃកំណត់ហេតុដើមរបស់អង្គជំនុំជម្រះសាលាដំបូង [...]"
>
> (ខ) វិធាន១០៩ ដល់វិធាន១១៤ មិនត្រូវអនុវត្តចំពោះបណ្តឹងឧទ្ធរណ៍បែបនេះទេ"។

២៣. វិធាន១០៩ ដល់វិធាន១១៤ នៃវិធាននីតិវិធីនិងភស្តុតាងរបស់តុលាការICTY និងICTR បានចែងអំពីវិធានការដែលត្រូវអនុវត្តនៅក្នុងដំណើរការនីតិវិធីឧទ្ធរណ៍ធម្មតា។ តាមរយៈនៃការមិនរួមបញ្ចូលវិធានការ "ធម្មតា" បែបនេះពីនីតិវិធីដែលមានចែងអំពីបណ្តឹងឧទ្ធរណ៍នៅក្នុងវិធាន៧៧ តុលាការICTY និងតុលាការICTY កំណត់ថា ការគ្រាន់តែពិនិត្យមើល "កំណត់ហេតុដើមរបស់ [ដំណើរការនីតិវិធីដំបូង]" គឺគ្រប់គ្រាន់ក្នុងការសម្រេចអំពីបណ្តឹងឧទ្ធរណ៍នេះ។ វិធានផ្ទៃក្នុងរបស់អ.វ.ត.ក



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

បានអនុវត្តនូវវិធីបែបនេះផងដែរ។ ទស្សនៈនេះត្រូវបានគាំទ្រដោយវិធាន៧៧(១) (ប្រយោគទីពីរ) នៃវិធានផ្ទៃក្នុងរបស់អ.វ.ត.កដែលបានចែងថា៖

> "បណ្តឹងឧទ្ធរណ៍ដែលមានចែងនៅក្នុង វិធាន៧៣(គ) ត្រូវដាក់ទៅក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះដែលត្រូវរក្សានូវសៀវភៅចុះបណ្តឹងឧទ្ធរណ៍ ហើយត្រូវជូនដំណឹងដល់ស្ថាប័នដែលចេញសេចក្តីសម្រេច និងស្នើសុំស្ថាប័ននេះផ្តល់រាល់ឯកសារពាក់ព័ន្ធ ប្រសិនបើចាំបាច់"។

២៤. បទប្បញ្ញត្តិនេះ មិនមែនជាការអនុវត្តន៍ចំពោះបណ្តឹងឧទ្ធរណ៍ផ្សេងៗទៀត ក្រោមយុត្តាធិការរបស់អង្គបុរេជំនុំជម្រះនោះទេ។

២៥. វិធានផ្ទៃក្នុងរបស់អ.វ.ត.ក មិនបានចែងអំពីតួនាទីរបស់សហព្រះរាជអាជ្ញានៅក្នុងករណីមានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច ដែលបានចែងនៅក្នុងវិធាន៣៥ និង/ឬ៣៨ នៃវិធានផ្ទៃក្នុង។ តាមការស្វែងរកការណែនាំដែលមាននៅក្នុងវិធានរបស់តុលាការICTY តុលាការICTR និងតុលាការ ICC ដូចដែលបានលើកឡើងពីមុន ដែលតុលាការទាំងនេះមិនបានចែងអំពីតួនាទីរបស់រដ្ឋអាជ្ញានៅក្នុងដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ការរកឃើញនេះ គឺអនុលោមតាមនីតិវិធីអន្តរជាតិ។

២៦. អង្គបុរេជំនុំជម្រះយល់ឃើញថា សហព្រះរាជអាជ្ញាមិនមែនជាភាគីមួយដោយស្វ័យប្រវត្តិទេ ហេតុដូចនេះ នៅក្នុងបណ្តឹងឧទ្ធរណ៍នេះ សហព្រះរាជអាជ្ញានឹងមិនចាំបាច់ចូលរួមក្នុងនាមជាភាគីទេ។

## III. តើដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ រួមទាំងដើមបណ្តឹងរដ្ឋប្បវេណីគ្មានមេធាវីតំណាង, សេង ចាន់ធារី ជាភាគីទៅនឹងបណ្តឹងឧទ្ធរណ៍នេះដែរឬទេ។

២៧. ភាគីនានានៅក្នុងសំណុំរឿង០០២ បានជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ ប៉ុន្តែមានភាពស្រពិចស្រពិលដំបូងទាក់ទឹងនឹងភាគីណាជាភាគីបណ្តឹងឧទ្ធរណ៍។ ឥឡូវ បញ្ហានេះនឹងត្រូវបានគេបកស្រាយថាតើ



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. * C.E.T.C.

ភាគីណាមួយមានសិទ្ធិជាភាគីដាក់ឯកសារចំពោះបណ្តឹងឧទ្ធរណ៍ និងបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយផ្អែកលើបទប្បញ្ញត្តិណាមួយ ហើយការដាក់សារណាពីភាគីផ្សេងៗទៀតអាចមិនសមស្រប។

២៨. នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៩ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សារណាទាក់ទងនឹងបណ្តឹងឧទ្ធរណ៍[14]។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា "ការពិភាក្សាអំពីតម្លាភាពនៃតុលាការ គឺមានលក្ខណៈចាំបាច់និងសំខាន់ណាស់ និងដីកាសម្រេចអំពីភាពសម្ងាត់ បានប៉ះពាល់ដល់ដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីការពារក្តីរបស់ពួកគាត់ផងដែរ"[15]។

២៩. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីរៀបរាប់ថា ពួកគាត់ "បានជួបប្រទះការលំបាកដូចសហមេធាវីការពារក្តីដែរ នៅពេលដែលមានការទាក់ទងនឹង៖ (i) គម្លាតពេលវេលាដ៏វែង រវាងការដាក់ឯកសារ និងការជូនដំណឹង និង(ii) ការដែលមិនអាចដឹងបានថាតើ ឯកសារមួយណានឹងត្រូវបានជ្រើសរើសយកទៅផ្សព្វផ្សាយនៅលើគេហទំព័ររបស់តុលាការ"[16]។

៣០. នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ ដើមបណ្តឹងរដ្ឋប្បវេណីគ្មានមេធាវីតំណាង សេង ចាន់ធារី បានដាក់សេចក្តីថ្លែងការណ៍ស្តីពីបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីការរំលោភបំពានការសម្ងាត់។ ដើមបណ្តឹងរដ្ឋប្បវេណីគ្មានមេធាវីតំណាង "សំណូមពរសុំសិទ្ធិក្នុងក្នុងការឡើងនិយាយដោយខ្លួនឯងផ្ទាល់ នៅក្នុងសវនាការអង្គបុរេជំនុំជម្រះ នាពេលខាងមុខនេះ លើករណី [បណ្តឹងឧទ្ធរណ៍] ប្រឆាំងនឹងដីកាសម្រេច [របស់សហចៅក្រមស៊ើបអង្កេត] អំពីការរំលោភបំពានការសម្ងាត់ [...] ដោយយោងទៅតាមសេចក្តីណែនាំជាសាធារណៈស្តីពីសិទ្ធិរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីគ្មានតំណាង ក្នុងការថ្លែងប្រាស្រ័យដោយផ្ទាល់នៅចំពោះមុខអង្គបុរេជំនុំជម្រះ"[17]។

[14] សេចក្តីថ្លែងការណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៩, D138/1/3។

[15] សេចក្តីថ្លែងការណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ៥។

[16] សេចក្តីថ្លែងការណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ៦។

[17] សេចក្តីថ្លែងការណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ៣។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRELIMINAIRE

៣១. នៅក្នុង "សេចក្តីឆ្លើយតបទៅនឹងសេចក្តីបង្គាប់ដែលចេញដោយអង្គបុរេជំនុំជម្រះ កាលពីថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩" ដែលដាក់នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៩ សហមេធាវីការពារក្តីលោក អៀង សារី យោងតែបន្តិចបន្តួចប៉ុណ្ណោះ[18] ទៅលើសេចក្តីថ្លែងការណ៍របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងមិនបានផ្តល់មតិយោបល់ដោយផ្ទាល់ថា តើសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី អាចចាត់ទុកថាជាភាគីនៅក្នុងនីតិវិធីឧទ្ធរណ៍នេះដែរឬទេ។ សហមេធាវីការពារក្តី "មិនបានលើកមតិយោបល់អ្វី ចំពោះសំណើរបស់ [ដើមបណ្តឹងរដ្ឋប្បវេណីគ្មានមេធាវីតំណាង] នោះទេ"[19]។

៣២. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា នីតិវិធីបណ្តឹងឧទ្ធរណ៍នេះពាក់ព័ន្ធនឹងសកម្មភាព ដូចដែលមានចែងនៅក្នុងវិធាន៣៥ និងវិធាន៣៨ នៃវិធានផ្ទៃក្នុង ហេតុដូចនេះនីតិវិធីនេះមានគោលបំណង និងវិសាលភាព ខុស គ្នាពីនីតិវិធីបណ្តឹងឧទ្ធរណ៍ផ្នែកព្រហ្មទណ្ឌ ដែលពាក់ព័ន្ធដល់ការការពារសិទ្ធិភាគីនានាក្នុងរឿងក្តីព្រហ្មទណ្ឌមួយចំនួន។ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងនីតិវិធីព្រហ្មទណ្ឌជាក់លាក់មួយចំនួនប៉ុណ្ណោះ និងអនុញ្ញាតឲ្យជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលស្ថិតក្រោមយុត្តាធិការគាំទ្រដល់ការចោទប្រកាន់ និងស្វែងរកសំណងផ្លូវចិត្ត និងសមូហភាព[20]។ ដោយសារតែសហព្រះរាជអាជ្ញាគ្មានសិទ្ធិនៅក្នុងនីតិវិធីនេះ ការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីក្នុងការគាំទ្រដល់សហព្រះរាជអាជ្ញា គឺមិនអាចអនុញ្ញាតបានទេនៅក្នុងបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ននេះ។ ការស្វែងរកសំណងមិនពាក់ព័ន្ធនោះទេ នៅក្នុងបណ្តឹងឧទ្ធរណ៍នេះដើម្បីផ្តល់នូវសិទ្ធិប្តឹងឧទ្ធរណ៍ចំពោះដើមបណ្តឹងរដ្ឋប្បវេណី។

---

[18] សេចក្តីឆ្លើយតបរបស់សហមេធាវីការពារក្តីតបនឹងសេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ៨ ចំណុចខ។

[19] សេចក្តីឆ្លើយតបរបស់សហមេធាវីការពារក្តីតបនឹងសេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ១០។

[20] វិធាន២៣(១)(ក) និង(ខ) នៃវិធានផ្ទៃក្នុងអ.វ.ត.ក។

## IV. សំណើសុំបើកសវនាការដេញដោលផ្ទាល់មាត់

៣៣. ទាំងនៅក្នុងបណ្តឹងឧទ្ធរណ៍ និងនៅក្នុងចម្លើយតបទៅនឹងសេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ សហមេធាវីការពារក្តីលោក អៀង សារី បានស្នើសុំឱ្យបើកសវនាការដេញដោលផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍នេះ[21]។ សហមេធាវីការពារក្តីបានតវ៉ាថា បញ្ហាសំខាន់ចាំបាច់ និង បញ្ហាផលប្រយោជន៍ នឹងត្រូវលើកយកមកពិចារណា ហេតុដូចនេះ ដោយយោងតាមវិធានផ្ទៃក្នុង ការសន្មតទុកជាមុនសម្រាប់គ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ទៅអង្គបុរេជំនុំជម្រះ គឺត្រូវមានសវនាការដេញដោលផ្ទាល់មាត់មួយ[22]។

៣៤. អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា វិធាន៧៧(១) នៃវិធានផ្ទៃក្នុង ចែងអំពីនីតិវិធីខុសគ្នា ទាក់ទងនឹងជំហាននីតិវិធីដំបូងដែលត្រូវអនុវត្ត នៅពេលដែលមានការដាក់បណ្តឹងឧទ្ធរណ៍ ដូចមានចែងនៅក្នុងវិធាន៧៣(គ)។ វិធាន៧៧(១)នៃវិធានផ្ទៃក្នុងចែងថា ចំពោះបណ្តឹងបែបនេះ ចំណាត់ការដំបូង គឺត្រូវជូនដំណឹងដល់ស្ថាប័នដែលចេញសេចក្តីសម្រេចឧទ្ធរណ៍ និងស្នើសុំស្ថាប័ននេះផ្តល់រាល់ឯកសារពាក់ព័ន្ធ ប្រសិនបើចាំបាច់។ ភាពខុសគ្នានៃការអនុវត្តន៍អនុវិធាន៧៧(១) នៃបណ្តឹងឧទ្ធរណ៍ក្រោមអនុវិធាន៧៣(គ) គឺជាចេតនា និងលើកឡើងអំពីភាពផ្សេងគ្នានៃបណ្តឹងឧទ្ធរណ៍នេះ បើប្រៀបធៀបនឹងបណ្តឹងឧទ្ធរណ៍ផ្សេងទៀត ដែលស្ថិតនៅក្នុងយុត្តាធិការអង្គបុរេជំនុំជម្រះ។ ហេតុដូចនេះ វិធានផ្ទៃក្នុងបានចែងអំពីការអនុវត្តន៍បណ្តឹងឧទ្ធរណ៍ ស្ថិតក្រោមវិធាន៧៣(គ) នៃវិធានផ្ទៃក្នុង ខុសគ្នាពីបណ្តឹងឧទ្ធរណ៍ផ្សេងទៀត ដែលមានក្រោមយុត្តាធិការរបស់អង្គបុរេជំនុំជម្រះ។

៣៥. វិធាន និងការអនុវត្តន៍របស់តុលាការអន្តរជាតិនានាចែងថា ប្រភេទនៃបណ្តឹងឧទ្ធរណ៍ដែលស្រដៀងគ្នានឹងបណ្តឹងឧទ្ធរណ៍នេះ អាចត្រូវបានសម្រេចទាំងស្រុងដោយផ្អែកលើសារណាជាលាយលក្ខណ៍

[21] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៨-១១ និងសេចក្តីឆ្លើយតបរបស់សហមេធាវីការពារក្តីតបនឹងសេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះកថាខណ្ឌ២-ឃ និង៧-៩។

[22] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១០។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C * C.E.T.C.

អក្សរ នៅក្នុងបណ្តឹងឧទ្ធរណ៍។ ចំពោះបណ្តឹងឧទ្ធរណ៍បែបនេះ វិធានដែលអនុវត្តធម្មតានៅក្នុងដំណើរការនីតិវិធីឧទ្ធរណ៍ផ្សេងទៀត "មិនត្រូវបានអនុវត្ត" ទេ[23]។

៣៦. ជាវិធានទូទៅ អង្គបុរេជំនុំជម្រះត្រូវពិចារណាលើបណ្តឹងឧទ្ធរណ៍ទាំងនេះ ដោយផ្អែកលើសារណាជាលាយលក្ខណ៍អក្សរ។ ដោយពិចារណាលើលក្ខណៈជាក់ស្តែងនៃនីតិវិធីឧទ្ធរណ៍បច្ចុប្បន្ន ដែលចែងថា គ្មានភាគីប្រឆាំងណាមួយមានសិទ្ធិប្តឹងឧទ្ធរណ៍ និងដោយសារអង្គបុរេជំនុំជម្រះមិនមានសំណួរដែលត្រូវសួរនៅក្នុងអំឡុងពេលសវនាការ អង្គបុរេជំនុំជម្រះបដិសេធសំណើបើកសវនាការដេញដោលផ្ទាល់មាត់។

**ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍**

៣៧. ដីកាសម្រេចអំពីភាពសម្ងាត់បានចេញនៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០០៩។ បណ្តឹងឧទ្ធរណ៍បានដាក់នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩ ដោយអនុលោមតាមរយៈពេលកំណត់ដែលមានចែងនៅក្នុងវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុងរបស់អ.វ.ត.ក។

៣៨. នៅក្នុងការតវ៉ាទាក់ទងនឹងការទទួលយកបណ្តឹងឧទ្ធរណ៍ សហមេធាវីការពារក្តីបានលើកឡើងថា៖

> "ដីកាសម្រេចស្តីពីភាពសម្ងាត់ គឺមានភាពមិនច្បាស់លាស់ទាក់ទងនឹងវិធានជាក់លាក់នានាដែលគេសំអាងក្នុងដីកានោះ។ ប៉ុន្តែ គេបានយោងទៅលើ "វិធាន៥៦(១)នៃវិធានផ្ទៃក្នុង និងមាត្រា ២១(៣) នៃកិច្ចព្រមព្រៀងឆ្នាំ២០០៣" ដែលមេធាវីការពារក្តីបានរំលោភបំពាន ដែលការរំលោភបំពាននេះ "អាចត្រូវដាក់ទណ្ឌកម្មតាមវិធាន៣៥ និង៣៨ នៃវិធានផ្ទៃក្នុង។

---

[23] សូមមើល កថាខណ្ឌ២២ និង២៣ ខាងលើ និងវិធាន១១៦ស្ទួន (ខ) នៃវិធាននីតិវិធីនិងភស្តុតាងរបស់តុលាការICTY និងវិធាន១១៧(ខ) នៃវិធាននីតិវិធីនិងភស្តុតាងរបស់តុលាការICTR។

វិធាន៣៥(៦) នៃ[វិធានផ្ទៃក្នុង]របស់ អ.វ.ត.ក(“វិធាន”) ចែងថា “រាល់សេចក្តីសម្រេច ដែលធ្វើឡើងក្រោមវិធាននេះ” អាចត្រូវប្តឹងឧទ្ធរណ៍ទៅអង្គជំនុំជម្រះ ឬប្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល។ សិទ្ធិប្តឹងឧទ្ធរណ៍នេះត្រូវបានទទួលយកដោយមាត្រា៧៣(គ) ដែលចែងអំពីយុត្តាធិការរបស់អង្គបុរេជំនុំជម្រះ។ វាប្រហែលជាគ្មានអ្វីគួរឱ្យឆ្ងល់ឡើយថា ដីកាស្តីពីការសម្ងាត់បង្កើតបានជា “សេចក្តីសម្រេចមួយតាមវិធាននេះ” ហេតុដូច្នេះហើយវាជាកម្មវត្ថុដែលត្រូវប្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ”[24]។

៣៩. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់សហមេធាវីការពារក្តីលោក អៀង សារី ថា វាគឺជាសិទ្ធិអំណាចរបស់ចៅក្រមក្នុងការសម្រេចថាតើពេលណា ឬដោយរបៀបណា ដែលត្រូវបើកបង្ហាញឯកសារសម្ងាត់នៅក្នុងសំណុំរឿងជាសាធារណៈនោះ[25]។ អង្គបុរេជំនុំជម្រះយល់ឃើញថា លិខិតនេះមិនបានបង្ហាញអំពីការសម្រេចដែលមាននៅក្នុងអត្ថន័យនៃភាព ដែលមានចែងនៅក្នុងមាត្រា៣.១២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅក្នុង អ.វ.ត.កនោះទេ។ ចំណុចសំខាន់នៃមាត្រា ៣.១២ គឺថា សេចក្តីសម្រេចណាមួយ ដែលចេញដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ ត្រូវពិនិត្យពិចារណាអំពីចំណាត់ប្រភេទ “ឯកសារមួយ ឬច្រើន” ដែលមិនមែនសំណុំរឿងទាំងមូលជាទូទៅនោះទេ។

៤០. នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចអំពីភាពសម្ងាត់[26] ដោយយល់ឃើញថា៖

> “ការសម្រេចចិត្តរបស់ក្រុមមេធាវីការពារក្តីក្នុងការបោះផ្សាយ [...] ឯកសារនានា ដែលជាការបំពានដោយផ្ទាល់ទៅលើសេចក្តីសម្រេចចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩ របស់សហចៅក្រមស៊ើប

---

[24] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៦ និង៧។

[25] អនុស្សរណៈផ្ទៃក្នុងរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតស្តីពីការរក្សាការសម្ងាត់នៃឯកសារសំណុំរឿង, ថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩, A238/1/Corr. 1។

[26] ដីកាសម្រេចអំពីភាពសម្ងាត់របស់សហចៅក្រមស៊ើបអង្កេត, ថ្ងៃទី៣ ខែមីនា ឆ្នាំ២០០៩, D138។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE
E.C.C.C. * C.E.T.C.

អង្កេត ហាមឃាត់មិនឱ្យមានការបោះផ្សាយរាល់ឯកសារសំណុំរឿង គឺជាការរំលោភលើវិធាន ៥៦(១) នៃវិធានផ្ទៃក្នុង និងមាត្រា២១(៣) នៃកិច្ចព្រមព្រៀង [...]”[27]។

និងបានលើកឡើងថា៖

“ការរំលោភបំពាននេះអាចត្រូវបានដាក់ទណ្ឌកម្ម តាមបទប្បញ្ញត្តិនៃវិធាន៣៥ និងវិធាន៣៨ នៃវិធានផ្ទៃក្នុង”[28]។

៤១. ផ្អែកលើមូលដ្ឋានទាំងនេះ សហចៅក្រមស៊ើបអង្កេតបានសម្រេចដូចខាងក្រោមនេះ៖

១. “មេធាវីទាំងពីររូបត្រូវធ្វើជាបន្ទាន់នូវកិច្ចដូចខាងក្រោម៖

ក) បញ្ឈប់ការផ្សព្វផ្សាយព័ត៌មាន ឬឯកសារនានា ដែលពាក់ព័ន្ធដល់កិច្ចស៊ើបសួរ លើកលែងចំពោះបណ្តាឯកសារទាំងឡាយណា ដែលមាននៅលើគេហទំព័ររបស់ អ.វ.ត.ក។

ខ) ធ្វើការដកចេញនូវរាល់ឯកសារ ដែលហាមឃាត់នោះចេញពីគេហទំព័ររបស់ខ្លួន។ ប្រសិនបើឯកសារទាំងអស់នោះមិនត្រូវបានដកចេញក្នុងរយៈពេល៤៨ ម៉ោងទេនោះ មេធាវីទាំងពីររូបនឹងត្រូវចាត់ទុកថា បានប្រព្រឹត្តការរំលោភបំពានថ្មីមួយទៀតលើដីកាសម្រេចនេះ។

២. ត្រូវចតចម្លងដីកានេះមួយច្បាប់ជូនដល់ស្ថាប័នដូចមានរាយនាមខាងក្រោម៖

ក) គ ណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ខ) គណៈមេធាវីសហរដ្ឋអាមេរិក

គ) គ ណៈមេធាវីរដ្ឋអាឡាស្កា (Alaska)

ឃ) អង្គភាពគាំពារការការពារក្តី

ដើម្បីអាចអនុញ្ញាតឱ្យស្ថាប័នទាំងនេះ ធ្វើការពិចារណាលើវិធានការដែលត្រូវបន្ត”។

---

[27] ដីកាសម្រេចអំពីភាពសម្ងាត់របស់សហចៅក្រមស៊ើបអង្កេត កថាខណ្ឌ១៩។

[28] ដីកាសម្រេចអំពីភាពសម្ងាត់របស់សហចៅក្រមស៊ើបអង្កេត កថាខណ្ឌ២០។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. * C.E.T.C.

៤២. វាមានការពាក់ព័ន្ធផងដែរ ក្នុងការពិចារណា វិធាន៥៦(១) វិធាន៣៥ និងវិធាន៣៨ នៃវិធានផ្ទៃក្នុង អ.វ.ត.ក និងមាត្រា៣.១២ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ និងមាត្រា២១(៣)នៃកិច្ចព្រមព្រៀង។

៤៣. នៅក្នុងអត្ថន័យនៃបទប្បញ្ញត្តិវិធាន៥៦ នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះកត់សម្គាល់ថា វាជាការត្រឹមត្រូវក្នុងការសន្និដ្ឋានថា សហមេធាវីការពារក្ដីបានប្រព្រឹត្តមិនស្របនឹងវិធានទូទៅនៃភាពសម្ងាត់ក្នុងការស៊ើបអង្កេត និងក្រមសីលធម៌វិជ្ជាជីវៈផ្នែកយុត្តិធម៌របស់ខ្លួន ដោយសារតែពួកគេបានបញ្ចេញផ្សព្វផ្សាយឯកសារក្នុងសំណុំរឿងនៅលើគេហទំព័រ ដោយមិនបានស្វែងរកការអនុញ្ញាតពីមន្ត្រីពាក់ព័ន្ធចំពោះឯកសារនីមួយៗជាមុននោះទេ។ យ៉ាងណាក៏ដោយ ការរកឃើញរបស់សហចៅក្រមស៊ើបអង្កេតដែលថា សហមេធាវីការពារក្ដីមិនបានគោរព "សេចក្ដីសម្រេច" ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩ និងបានរំលោភលើវិធាន៣៥ នៃវិធានផ្ទៃក្នុង គឺជាការយល់ឃើញដែលមិនត្រឹមត្រូវ។

៤៤. លិខិតរបស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩ មិនមែនជា "ដីកាសម្រេច" ហើយអត្ថិភាពនៃ "ដីកាសម្រេច" និង"ការរំលោភបំពាន" ដីកានេះ គឺចាំបាច់មានជាមុន ដើម្បីអាចអនុវត្តវិធាន៣៥ នៃវិធានផ្ទៃក្នុង ក្នុងករណីចេញផ្សាយព័ត៌មានសម្ងាត់។ ហេតុដូច្នេះ ដីកាសម្រេចភាពសម្ងាត់ ត្រូវបានរកឃើញថា មិនមែនជា "សេចក្ដីសម្រេចដែលមានចែងនៅក្នុងវិធាន៣៥ នៃវិធានផ្ទៃក្នុង" នោះទេ។ គ្មាន "ដីកាសម្រេច" ណាមួយត្រូវបាន "រំលោភបំពាន" នៅក្នុងវិសាលភាពនៃវិធាន៣៥(១)(ក)នៃវិធានផ្ទៃក្នុង ដែលសហចៅក្រមស៊ើបអង្កេតយោងលើវិធាននេះ នៅពេលធ្វើការសម្រេចរបស់ខ្លួន។

៤៥. នៅក្នុងផ្នែកសន្និដ្ឋាននៃដីកាសម្រេចភាពសម្ងាត់នៅចំណុច(១)(ក) ដែលសម្រេចឱ្យសហមេធាវីការពារក្ដី "បញ្ឈប់ការផ្សព្វផ្សាយព័ត៌មាន ឬឯកសារនានា ដែលពាក់ព័ន្ធដល់កិច្ចស៊ើបសួរលើកលែងចំពោះបណ្ដាឯកសារទាំងឡាយណា ដែលមាននៅលើគេហទំព័ររបស់អ.វ.ត.ក" អង្គបុរេ



E.C.C.C * C.E.T.C
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ជំនុំជម្រះកត់សម្គាល់បន្ថែមថា ដីកាសម្រេចភាពសម្ងាត់ គឺជាប្រភេទនៃដីកាសម្រេចដែលបិទផ្លូវតវ៉ាចំពោះមុខអង្គបុរេជំនុំជម្រះដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង។ សិទ្ធិប្តឹងឧទ្ធរណ៍មិនមានចែងទាល់តែសោះក្នុងវិធាន៣៨ បញ្ជាក់ពីមានទទួលរងការដាក់វិន័យ ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដូចមានចែងនៅក្នុងវិធាន៣៨(៣)នៃវិធានផ្ទៃក្នុង។ ដោយសារតែបណ្តឹងឧទ្ធរណ៍បានដាក់ប្រឆាំងនឹងផ្នែកនេះ ហេតុដូច្នេះបណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានទេ។

៤៦. បន្ថែមពីលើកនេះ នៅក្នុងផ្នែកសន្និដ្ឋាននៅចំណុច (១)(ខ) ដែលសម្រេចឱ្យសហមេធាវីការពារក្តី “ធ្វើការដកចេញនូវរាល់ឯកសារ ដែលហាមឃាត់នោះ ចេញពីគេហទំព័ររបស់ខ្លួន” ដីកាសម្រេចភាពសម្ងាត់តំណាងឱ្យប្រភេទដីកាសម្រេច ដែលមិនអាចប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ដោយសារតែមូលហេតុដូចគ្នានោះដែរ។

៤៧. ប្រយោគទីពីរក្នុងផ្នែកនៃដីកាសម្រេចនេះ ដែលលើកឡើងថា “ប្រសិនបើឯកសារទាំងអស់នោះ មិនត្រូវបានដកចេញក្នុងរយៈពេល៤៨ ម៉ោងទេនោះ មេធាវីទាំងពីររូបនឹងត្រូវចាត់ទុកថា បានប្រព្រឹត្តការរំលោភបំពានថ្មីមួយទៀតលើដីកាសម្រេចនេះ នឹងត្រូវប្រឈមមុខទទួលចំណាត់ការផ្នែកច្បាប់” គឺជាការព្រមាននៅក្នុងអត្ថន័យនៃបទប្បញ្ញត្តិដែលមានចែងនៅក្នុងវិធាន៣៨(១) នៃវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះយល់ឃើញថា ការព្រមាននេះយោងទៅនឹងលទ្ធភាពនៃការប្រព្រឹត្តិដែលជា *“ការរំលោភបំពានថ្មី (une nouvelle violation)”* នៃដីកាសម្រេច។ នៅក្នុងសំណៅជាភាសាអង់គ្លេសនៃដីកាសម្រេចភាពសម្ងាត់ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា សំណៅនេះត្រូវបានបកប្រែជា “ការរំលោភបំពានបន្ថែម (further breach)”។ ដោយពិចារណាអំពីដីកាសម្រេចដើមជាភាសាបារាំង សំណៅភាសាអង់គ្លេសគួរតែប្រើប្រាស់ពាក្យ “ការរំលោភបំពានថ្មីវិញ (new violation)”។

៤៨. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ផ្នែកនៃដីកាសម្រេចនេះមិនមែនជា “ការដាក់វិន័យដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា” ដូចមានចែងនៅក្នុងវិធាន៣៨(៣)នៃវិធានផ្ទៃក្នុងនោះទេ។ អនុ



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C.

ឈោមតាមវិធាន៣៨ នៃវិធានផ្ទៃក្នុង "ការព្រមាន" បិទផ្លូវតវ៉ាចំពោះមុខអង្គបុរេជំនុំជម្រះ។ ហេតុដូច្នេះ ផ្នែកនៃបណ្តឹងឧទ្ធរណ៍នេះ មិនអាចទទួលយកបានទេ។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេច៖**

បណ្តឹងឧទ្ធរណ៍នេះ មិនអាចទទួលយកបានទេ។ ///

ភ្នំពេញ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៩

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

**Rowan DOWNING** **នេយ ធុល** **Katinka LAHUIS** **ហួត វុទ្ធី**

**ក្រឡាបញ្ជី**

**សរ ចំន្ទរ៉ា** **Entela JOSIFI**